# សាធារណរដ្ឋប្រជាមានិតកម្ពុជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់

## ស្តីពី

## ការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការ

## អមតុលាការប្រជាជនកំពូល

-មាត្រា១ -ត្រូវបានបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការ អមតុលាការប្រជាជនកំពូល នៅសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

-មាត្រា២ -តុលាការប្រជាជនកំពូល ជាស្ថាប័នជំនុំជម្រះខ្ពស់បំផុត នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

-មាត្រា៣ -តុលាការប្រជាជនកំពូល មានសមត្ថកិច្ចដូចទៅ៖

-ជំនុំជម្រះជាលើកទី១ និង ជាលើកចុងក្រោយបង្អស់នូវរឿងទាំងឡាយ ដែលច្បាប់កំណត់ថាជាសមត្ថកិច្ចរបស់ខ្លួន ។

-ជំនុំជម្រះបណ្តឹងសាទុក្ខរបស់ប្រធានតុលាការកំពូល ឬ របស់អគ្គរដ្ឋអាជ្ញា ពីសាលក្រម ដែលមានអានុភាពអនុវត្តសម្រេចដោយសភាតុលាការកំពូល ឬ ដោយតុលាការប្រជាជន ខេត្ត-ក្រុង និងតុលាការយោធា។

-ពិនិត្យសាលក្រមប្រហារជីវិត មុនពេលដាក់ជូនក្រុមប្រឹក្សារដ្ឋសម្រេច។

-ត្រួតពិនិត្យ និង តាមដានការងាររបស់តុលាការប្រជាជន ខេត្ត-ក្រុង និងតុលាការយោធា ។